# អគ្គនាយកដ្ឋានពន្ធដារ

# សៀវភៅណែនាំ

## ស្តីពី

## ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្ម អនឡាញ
## មុខងារ៖ ស្នើសុំកែតម្រូវលិខិតប្រកាសពន្ធ

ជំនាន់. ១.៦.០

២០២៣

## សម្រាប់អ្នកជាប់ពន្ធ

www.tax.gov.kh
Call center: 1277
t.me/gdtcambodianews
www.youtube.com/@generaldepartmentoftaxation

រៀបចំដោយ៖ នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

© រក្សាសិទ្ធិអគ្គនាយកដ្ឋានពន្ធដារ

# © រក្សាសិទ្ធិអ្នករៀបរៀង

សៀវភៅណែនាំស្តីពីការប្រើប្រាស់ **ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្ម អនឡាញ មុខងារៈ ស្នើសុំកែតម្រូវលិខិតប្រកាសពន្ធ** គឺជាកម្មសិទ្ធិរបស់អគ្គនាយកដ្ឋានពន្ធដារ។ រាល់ការផលិត ឬថតចម្លងឡើងវិញនូវស្នាដៃនេះ ទោះបីទាំងស្រុងក្តី ឬជាភាគក្តី និងតាមរយៈការប្រើមធ្យោបាយណាក៏ដោយត្រូវបានហាមឃាត់ជាដាច់ខាត កាលបើពុំមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីសំណាក់អ្នករៀបរៀងទេនោះ។

ការបំពានលើសិទ្ធិអ្នករៀបរៀង គឺជាបទល្មើសព្រហ្មទណ្ឌដែលត្រូវទទួលការផ្តន្ទាទោសពិន័យជាប្រាក់ និងដាក់ពន្ធនាគារដោយអនុលោមតាមច្បាប់ស្តីពីសិទ្ធិអ្នករៀបរៀង និងសិទ្ធិប្រហាក់ប្រហែល ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ និងត្រូវផ្តន្ទាទោសឱ្យទទួលខុសត្រូវផ្នែករដ្ឋប្បវេណីចំពោះព្យសនកម្មដែលបានបង្កឡើង។

# អារម្ភកថា

វឌ្ឍនភាពនៃវិទ្យាសាស្ត្រ វិស្វកម្ម និងបច្ចេកវិទ្យា គឺជាគន្លឹះដ៏សំខាន់ក្នុងការជំរុញការផ្លាស់ប្ដូររបស់ពិភពលោកឱ្យកាន់តែមានការរីកចម្រើនឥតឈប់ឈរជាលំដាប់។ បច្ចុប្បន្ននេះ ពិភពលោកកំពុងតែស្ថិតក្នុងដំណាក់កាលនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤.០ ដែលផ្ដោតជាសំខាន់លើបរិវត្តកម្មឌីជីថល។ បច្ចេកវិទ្យាឌីជីថល និងបច្ចេកវិទ្យាព័ត៌មានបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកគាំទ្រ និងជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ធានាបាននូវកំណើន និងគុណភាពនៃផលិតកម្ម និងសេវាកម្ម ពង្រឹងបាននូវអភិបាលកិច្ចល្អ តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាពនៅក្នុងស្ថាប័ន និងបង្កើតឱ្យមាននូវនវានុវត្តន៍ថ្មីៗបន្ថែមទៀតដែលជាប្រយោជន៍ដល់ការអភិវឌ្ឍ សេដ្ឋកិច្ច និងសង្គមជាតិ។ ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (Information and Communication Technology) របស់រដ្ឋាភិបាលកម្ពុជា ដោយផ្ដោតសំខាន់លើវិធីសាស្ត្រនៃការគ្រប់គ្រង ការប្រើប្រាស់ឧបករណ៍ និងកម្មវិធីបច្ចេកវិទ្យាព័ត៌មាន បានធ្វើឱ្យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្លាយជាឧបករណ៍ដ៏មានសារៈសំខាន់ និងចាំបាច់ក្នុងការផ្ដល់សេវាកម្មសាធារណៈជូនប្រពលរដ្ឋ និងពង្រឹងអភិបាលកិច្ចល្អ ប្រកបដោយប្រសិទ្ធភាព និងស័ក្ដិសិទ្ធិភាព។ ផ្អែកទៅលើកាលានុវត្តភាពនេះ ព្រះរាជាណាចក្រកម្ពុជាបាន និងកំពុងខិតខំស្វះស្វែង និងពុះពារគ្រប់ឧបសគ្គជាច្រើន ក្នុងការបង្កើត និងធ្វើទំនើបកម្មប្រព័ន្ធពន្ធដារឱ្យមានសមត្ថភាពពេញលេញក្នុងការគ្រប់គ្រង និងប្រមូលចំណូលពន្ធគ្រប់ប្រភេទ សម្រាប់អភិវឌ្ឍប្រទេសជាតិស្របតាមយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០២៤-២០២៨ របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានទៅសម្រេចបាននូវចក្ខុវិស័យនៃការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ និងប្រទេសមានចំណូលកម្រិតខ្ពស់ នៅឆ្នាំ២០៥០។

អគ្គនាយកដ្ឋានពន្ធដារបានខិតខំអភិវឌ្ឍ ប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយមានមុខងារសំខាន់ក្នុងការគ្រប់គ្រងប្រមូលផ្ដុំទិន្នន័យនៃព័ត៌មានទាំងអស់ក្នុងប្រព័ន្ធតែមួយ (Centralized Database System) ដែលជួយសម្រួលដល់មន្ត្រីនិងថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ ក្នុងការរៀបចំផែនការសកម្មភាពការងារ ការអនុវត្តការងារប្រចាំថ្ងៃ ការតាមដានត្រួតពិនិត្យវាយតម្លៃលទ្ធផលការងារ ការកំណត់បញ្ហានានា និងការស្វែងរកដំណោះស្រាយនៃបញ្ហា ក្នុងន័យជំរុញការងារប្រតិបត្តិស្នូល និងការងារគាំទ្រឱ្យប្រព្រឹត្តទៅប្រកបដោយ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ បន្ថែមលើនេះទៀត ប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារបានជួយសម្រួលដល់មន្ត្រី និងថ្នាក់ដឹកនាំរបស់អគ្គនាយកដ្ឋានពន្ធដារ តាមរយៈការកាត់បន្ថយភាពស្មុគស្មាញនានាក្នុងការបំពេញបែបបទរដ្ឋបាល កាត់បន្ថយរយៈពេលនៃការបញ្ជូនឯកសារពីកម្រិតមន្ត្រី រហូតដល់ថ្នាក់ដឹកនាំ ផ្ដល់ភាពងាយស្រួលដល់ថ្នាក់ដឹកនាំ ក្នុងការគ្រប់គ្រងវាយតម្លៃប្រសិទ្ធភាពការងាររបស់មន្ត្រីក្រោមឱវាទ ក្នុងគោលបំណងធានាឱ្យបាននូវការបំពេញកាតព្វកិច្ចការងារក្នុងអគ្គនាយកដ្ឋានពន្ធដារ ប្រកបដោយប្រសិទ្ធភាពដើម្បីសម្រេចបានគោលដៅដែលបានកំណត់។

ដើម្បីជំរុញការអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមបច្ចេកវិទ្យាព័ត៌មាន ឱ្យបានរលូន និងកាន់តែមានប្រសិទ្ធភាពស្របតាមផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានពន្ធដារបានរៀបចំ **ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្ម អនឡាញ មុខងារៈ ស្នើសុំកែតម្រូវលិខិតប្រកាសពន្ធ** ដើម្បីឱ្យមន្ត្រី និងថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ និងអ្នកជាប់ពន្ធ អាចចូលទៅប្រើប្រាស់ ប្រព័ន្ធតាមវិហរការងារ និងទាញយកទិន្នន័យមកប្រើប្រាស់ ប្រកបដោយជំនឿទុកចិត្ត គុណភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាព ដែលជាមូលដ្ឋានគ្រឹះនៃការជំរុញនិងលើកកម្ពស់កម្រិតសមត្ថភាពក្នុងការបំពេញការងារ។

សៀវភៅណែនាំនេះត្រូវបានរៀបចំឡើង ក្នុងគោលបំណងផ្ដល់ការណែនាំកម្រិតលម្អិតក្បោះក្បាយ និងច្បាស់លាស់ដល់អ្នកប្រើប្រាស់អំពីរបៀបនៃការប្រើប្រាស់ប្រព័ន្ធ កម្មវិធីរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីជំរុញឱ្យការបំពេញភារៈកិច្ចឱ្យបានប្រសើរ ដោយផ្ដល់ជូនអ្នកប្រើប្រាស់ នូវមុខងារមួយចំនួនដូចជា៖

១. បង្កើតគណនី e-Tax ថ្មី

២. បញ្ចូលព័ត៌មានកែតម្រូវប្រចាំខែ (មានទិនានុប្បវត្តិទិញ លក់ ពន្ធកាត់ទុក និងពន្ធលើប្រាក់បៀវត្សនិងពន្ធលើអត្ថប្រយោជន៍បន្ថែម)

៣. ប្រកាសពន្ធកែតម្រូវប្រចាំខែ និងដាក់ពាក្យស្នើសុំកែតម្រូវ

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមយ៉ាងមុតមាំថា អ្នកអានទាំងអស់នឹងឈ្វេងយល់ពីការប្រើប្រាស់ ប្រព័ន្ធ-កម្មវិធីពន្ធដារ តាមរយៈឯកសារបណ្តុះបណ្តាលនានា ជាពិសេស សៀវភៅណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ នេះ ដើម្បីបង្កើនសមត្ថភាពក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធឱ្យបានកាន់តែប្រសើរឡើង ដែលជាការចូលរួមចំណែកមួយដ៏ធំធេង និងមានសារសំខាន់ក្នុងដំណើរការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**មាតិកា** **ទំព័រ**

## ជំពូកទី១ៈ ទិដ្ឋភាពទូទៅ

១.១ សេចក្តីផ្តើម ........ ១
១.២ វិសាលភាព ........ ១
១.៣ ប្រវត្តិកំណែប្រែ ........ ១
១.៤ សង្ខេបរំហូរនៃការប្រើប្រាស់ប្រព័ន្ធ ........ ១

## ជំពូកទី២ៈ ការប្រើប្រាស់ប្រព័ន្ធ

២.១ តម្រូវការនៃការប្រើប្រាស់ប្រព័ន្ធ ........ ២
២.២ បង្កើតគណនីប្រើប្រាស់(User) ........ ២
២.៣ ការចូលប្រើប្រាស់ប្រព័ន្ធ ........ ៣
២.៤ ការបញ្ចូលព័ត៌មានកែតម្រូវលិខិតប្រកាស ........ ៥
២.៤.១ បញ្ជីកែតម្រូវទិនានុប្បវត្តិទិញ-លក់ ........ ៥
២.៤.២ បញ្ជីកែតម្រូវពន្ធកាត់ទុក ........ ១៤
២.៤.៣ បញ្ជីកែតម្រូវពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ........ ១៦
២.៥ ការប្រកាសពន្ធកែតម្រូវប្រចាំខែ ........ ១៩
២.៦ បញ្ជីប្រកាសពន្ធកែតម្រូវប្រចាំខែ ........ ២០
២.៦.១ បោះពុម្ពពាក្យស្នើសុំកែតម្រូវ ........ ២០
២.៦.២ បោះពុម្ពលិខិតបញ្ជាក់ការបង់ពន្ធកែតម្រូវ ........ ២១
២.៦.៣ បោះពុម្ពលិខិតអនុញ្ញាតកែតម្រូវ ........ ២២
២.៦.៤ បោះពុម្ពលិខិតបដិសេធកែតម្រូវ ........ ២៣

# ជំពូកទី១៖ ទិដ្ឋភាពទូទៅ

## ១.១ សេចក្តីផ្តើម

ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្ម អនឡាញ(e-filing) មុខងារ៖ស្នើសុំកែតម្រូវលិខិតប្រកាសពន្ធប្រចាំខែ ត្រូវបានបង្កើតឡើង ដើម្បីជួយសម្រួលដល់អ្នកជាប់ពន្ធ ក្នុងការស្នើសុំកែតម្រូវលិខិតប្រកាសពន្ធប្រចាំខែ តាមប្រព័ន្ធអនឡាញ ដោយវាយបញ្ចូលនូវព័ត៌មានប្រកាសពន្ធកែតម្រូវមានបញ្ជីទិញ-លក់ ពន្ធកាត់ទុក និងពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម និងចុចប៊ូតុងដាក់ពាក្យស្នើសុំជាការស្រេច មិនចាំបាច់យកពាក្យមកដាក់នៅអគ្គនាយកដ្ឋានពន្ធដារ ទៀតទេ។

## ១.២ វិសាលភាព

ប្រព័ន្ធនេះមានវិសាលភាពប្រើប្រាស់ សម្រាប់សហគ្រាសធុនមធ្យម និងធំដែលបានប្រកាសពន្ធប្រចាំខែតាមអនឡាញកន្លងមក។ ប្រព័ន្ធនេះមានមុខងារ សំខាន់ៗដូចជា៖

- បញ្ចូលព័ត៌មានកែតម្រូវប្រចាំខែ (មានទិនានុប្បវត្តិទិញ លក់ ពន្ធកាត់ទុក និងពន្ធលើប្រាក់បៀវត្សនិងពន្ធលើអត្ថប្រយោជន៍បន្ថែម)
- ប្រកាសពន្ធកែតម្រូវប្រចាំខែ និងដាក់ពាក្យស្នើសុំកែតម្រូវ

## ១.៣ ប្រវត្តិកំណែប្រែ

| ល.រ | បរិយាយ | កាលបរិច្ឆេទ | ជំនាន់ |
|---|---|---|---|
| ១ | រៀបចំដំបូង | ០៦ វិច្ឆិកា ២០២៣ | ១.៦.០ |

## ១.៤ សង្ខេបរំហូរនៃការប្រើប្រាស់ប្រព័ន្ធ

LOGIN ឬ ចុះឈ្មោះបង្កើតគណនីសម្រាប់ប្រើប្រាស់ប្រព័ន្ធតាមរយៈគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ
https://www.tax.gov.kh

១. ជ្រើសរើសសហគ្រាស
២. មុខងារស្នើសុំកែតម្រូវលិខិតប្រកាសពន្ធប្រចាំខែ

៣. បញ្ចូលប្រតិបត្តិការកែតម្រូវ ( ទិញ លក់ ពន្ធកាត់ទុក និងពន្ធលើប្រាក់បៀវត្សនិងអត្ថប្រយោជន៍បន្ថែម)

៤. ប្រកាស ពន្ធ លើការកែតម្រូវប្រចាំខែ និងដាក់ពាក្យស្នើសុំ
៥. **ករណីមានប្រាក់ពន្ធត្រូវបង់** ត្រូវយកបារកូដទៅបង់នៅធនាគារ ឬតាមប្រព័ន្ធ e-Payment

៦.-**ករណីទទួលបានការឯកភាព**លើការស្នើសុំលោកអ្នកអាចបោះពុម្ពឥណទានយោងយកទៅយោងបាន
-**ករណីទទួលបានការបដិសេធ**លើការស្នើសុំលោកអ្នកអាចធ្វើការកែតម្រូវនិងដាក់ពាក្យស្នើសុំសារជាថ្មី

រូបភាពទី 1៖ រំហូរនៃការប្រើប្រាស់ប្រព័ន្ធ

# ជំពូកទី២៖ ការប្រើប្រាស់ប្រព័ន្ធ

## ២.១ តម្រូវការនៃការប្រើប្រាស់ប្រព័ន្ធ

ដើម្បីចូលប្រើប្រាស់ប្រព័ន្ធនេះបានលោកអ្នកត្រូវមាន៖

- កុំព្យូទ័រដែលមានភ្ជាប់បណ្តាញផ្ទៃអ៊ីនធឺណិត និងកម្មវិធី Browser Chrome ឬ Firefoxជំនាន់ថ្មី
- អាសយដ្ឋានសម្រាប់ចូលប្រើប្រាស់ប្រព័ន្ធ៖ https://owp.tax.gov.kh/gdtowpcoreweb/login
- គណនី (ឈ្មោះ និងពាក្យសម្ងាត់) ដែលបង្កើតដោយខ្លួនឯង
- សូមអនុញ្ញាតឱ្យផ្ទាំង POP-UP ដំណើការបាន
  - របៀបដោះ Pop-up តាមរយៈកម្មវិធី Browser Firefox សូមវាយពាក្យខាងក្រោមនៅក្នុងប្រអប់អាសយដ្ឋាន ៖ about:preferences#privacy។ សូមលោក លោកស្រីពិនិត្យមើលពាក្យ Privacy & Security បន្ទាប់មកពិនិត្យមើលពាក្យ Block pop-up windows និងសូមដោះធីកចេញជាការរួចរាល់។
  - របៀបដោះ Pop-up តាមរយៈកម្មវិធី Browser Chrome សូមវាយពាក្យខាងក្រោមនៅក្នុងប្រអប់អាសយដ្ឋាន៖chrome://settings/content/popups សូមលោក លោកស្រី ពិនិត្យមើលពាក្យ Allowed និងសូមចុចលើប៊ូតុងខាងស្តាំឱ្យបើកដំណើរការជាការរួចរាល់ ។

## ២.២ បង្កើតគណនីប្រើប្រាស់( User )

ប្រសិនបើលោក លោកស្រីមិនទាន់មានគណនីចូលប្រើប្រាស់ប្រព័ន្ធទេសូមចូលទៅបង្កើតគណនីថ្មី ដោយចុចលើតំណភ្ជាប់បង្កើតគណនីថ្មី ប្រព័ន្ធនឹងចេញផ្ទាំងសម្រាប់បញ្ចូលព័ត៌មានតម្រូវរបស់លោក លោកស្រី បន្ទាប់មកចុចប៊ូតុងបន្ទាប់ ប្រព័ន្ធនឹងផ្ញើសារជាលីងទៅកាន់អ៊ីម៉ែលរបស់លោក លោកស្រី និងចេញផ្ទាំងផ្ទៀងផ្ទាត់អ៊ីម៉ែលបើសិនជាលោកលោកស្រីមិនឃើញ អ៊ីម៉ែលដែលប្រព័ន្ធផ្ញើទៅទេ សូមចុចតំណភ្ជាប់ផ្ញើម្តងទៀត បន្ទាប់មកសូមធ្វើតាមសេចក្តីណែនាំក្នុងសារអេឡិចត្រូនិករបស់លោក លោកស្រី ប្រព័ន្ធនឹងឱ្យលោក លោកស្រីបញ្ចូលពាក្យសម្ងាត់ថ្មី ដូចលំនាំខាងក្រោម៖






រូបភាពទី 2៖ បង្កើតគណនីថ្មី

## ២.៣ ការចូលប្រើប្រាស់ប្រព័ន្ធ

លោក លោកស្រីសូមចូលទៅកាន់តំណភ្ជាប់: https://owp.tax.gov.kh/gdtowpcoreweb/login

លោក លោកស្រីអាចចូលប្រើប្រព័ន្ធបាន បីប្រភេទ៖

- តាមរយៈ MOI ID
  - សូមចុចលើ MOI ID
  - បញ្ចូលលេខអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន
  - បញ្ចូលពាក្យសម្ងាត់
  - ចុចប៊ូតុងចូលប្រើប្រព័ន្ធ
- តាមរយៈអ៊ីម៉ែល
  - សូមចុចលើអ៊ីម៉ែល
  - បញ្ចូលអ៊ីម៉ែល
  - បញ្ចូលពាក្យសម្ងាត់
  - ចុចប៊ូតុងចូលប្រើប្រព័ន្ធ
- តាមរយៈ TID
  - សូមចុចលើ TID
  - សូមបញ្ចូលលេខសម្គាល់ការចុះបញ្ជីព័ត៌មានបុគ្គល (TID)
  - បញ្ចូលពាក្យសម្ងាត់
  - ចុចប៊ូតុងចូលប្រើប្រព័ន្ធ
- ចុចលើរូបប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មប្រចាំខែ អនឡាញ




រូបភាពទី 3 ៖ ការចូលប្រើប្រាស់ប្រព័ន្ធ

## ២.៤ ការចុះឈ្មោះសហគ្រាស

- ចុះឈ្មោះសហគ្រាសស្នើសុំ
  - បញ្ចូល IP Address ដែលបានទទួលពីក្រុមហ៊ុនផ្ដល់សេវាអ៊ីនធឺណេត ឬចុចប៊ូតុង Get IP
  - បញ្ចូលលេខអត្តសញ្ញាណកម្មសារពើពន្ធ (បញ្ចូលលេខ អតប)
  - បញ្ចូលលេខកាតសម្គាល់ការចុះបញ្ជីពន្ធដារ (TID)
  - បញ្ចូលលេខទូរស័ព្ទម្ចាស់ភាគហ៊ុនឈរឈ្មោះលើប័ណ្ណប៉ាតង់ រួចចុចប៊ូតុង បន្ទាប់
  - សូមបញ្ចូលលេខកូដដែលបានផ្ញើទៅកាន់ទូរសព្ទដៃ របស់ម្ចាស់ភាគហ៊ុនឈរឈ្មោះលើប័ណ្ណប៉ាតង់ រួចចុចប៊ូតុង ផ្ទៀងផ្ទាត់៖




រូបភាពទី 4 ÷ ការចុះឈ្មោះសហគ្រាស

## ២.៤ ការបញ្ចូលព័ត៌មានកែតម្រូវលិខិតប្រកាស

សូមលោក លោកស្រីចុចលើប៊ូតុងស្វែងរក រួចចុចលើប៊ូតុងសញ្ញារូបចុចបីនៃសហគ្រាសណាមួយដែលត្រូវស្នើសុំកែតម្រូវ សូមចុចលើកែតម្រូវលិខិតប្រកាសពន្ធ៖




រូបភាពទី 5 ÷ បញ្ចូលព័ត៌មានកែតម្រូវលិខិតប្រកាស

### ២.៤.១ បញ្ជីកែតម្រូវទិនានុប្បវត្តិទិញ-លក់

សូមលោក លោកស្រីចុចលើម៉ឺនុយ **កែតម្រូវលិខិតប្រកាសពន្ធ** ចុចលើ **បញ្ជីកែតម្រូវទិនានុប្បវត្តិទិញ-លក់** ៖

➢ **កែតម្រូវការទិញ**

ការកែតម្រូវការទិញ លោក លោកស្រីអាចបន្ថែមវិក្កយបត្រថ្មីចំពោះការខកខានមិនបានបញ្ចូល អាចកែប្រែព័ត៌មានវិក្កយបត្រដែលខុស ឬអាចលុបចោល ពេលដែលប្រកាសពន្ធប្រចាំខែខុស។

- សូមចុច **ការទិញទំនិញ និងសេវា(ធាតុចូល)**
- ករណីបន្ថែមប្រតិបត្តិការទិញ ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ** សូមចុចលើ ប៊ូតុង**បន្ថែមប្រតិបត្តិការ** សូមបំពេញព័ត៌មានឲ្យបានត្រឹមត្រូវ បន្ទាប់មកសូមចុចប៊ូតុង **រក្សាទុក និងបន្ថែមថ្មី**




រូបភាពទី 6 ៖ បន្ថែមប្រតិបត្តិការទិញ

- ករណីកែប្រែប្រតិបត្តិការទិញ ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ** សូមចុចលើ ប៊ូតុង **កែប្រែប្រតិបត្តិការ** សូមស្វែងរកតាមលេខវិក្កយបត្រ ចុចប៊ូតុង**កែប្រែវិក្កយបត្រ** សូមបំពេញព័ត៌មានឲ្យបានត្រឹមត្រូវ បន្ទាប់មកសូមចុចប៊ូតុង **រក្សាទុក និងបន្ថែមថ្មី**




រូបភាពទី 7 ÷ កែប្រែប្រតិបត្តិការទិញ

- ករណីលុបប្រតិបត្តិការទិញ ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ** សូមចុចលើ ប៊ូតុង **លុបប្រតិបត្តិការ** សូមស្វែងរកតាមលេខវិក្កយបត្រ ចុចប៊ូតុង**លុបវិក្កយបត្រ** បន្ទាប់មកសូមបញ្ចូលមូលហេតុ រួចសូមចុចប៊ូតុង **យល់ព្រម**




រូបភាពទី 8 ÷ លុបប្រតិបត្តិការទិញ

- ករណីមើលព័ត៌មាននៃការកែតម្រូវប្រតិបត្តិការទិញ ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ** សូមចុចលើ ប៊ូតុង **ពិនិត្យព័ត៌មានលម្អិតនៃការកែតម្រូវ** អាចស្វែងរកតាមលេខវិក្កយបត្រ ឬប្រតិវេទគយ និងលេខសម្គាល់ចុះបញ្ជីពន្ធដារ សូមចុចប៊ូតុង **ស្វែងរក**



រូបភាពទី 9 ÷ មើលព័ត៌មានការកែតម្រូវប្រតិបត្តិការទិញ

➢ **កែតម្រូវការលក់**

ការកែតម្រូវការលក់ លោក លោកស្រីអាចបន្ថែមវិក្កយបត្រថ្មីចំពោះការខកខានមិនបានបញ្ចូល អាចកែប្រែព័ត៌មានវិក្កយបត្រដែលខុស ឬអាចលុបវិក្កយបត្រចេញ។

- សូមចុច **ការលក់ទំនិញ និងសេវា (ជាតុចេញ)**
- ករណីបន្ថែមប្រតិបត្តិការលក់ ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ** សូមចុចលើ ប៊ូតុង**បន្ថែមប្រតិបត្តិការ** សូមបំពេញព័ត៌មានឲ្យបានត្រឹមត្រូវ បន្ទាប់មកសូមចុចប៊ូតុង **រក្សាទុក និងបន្ថែមថ្មី**






រូបភាពទី 10 ÷ បន្ថែមប្រតិបត្តិការលក់

- ករណីកែប្រែប្រតិបត្តិការលក់ ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ** សូមចុចលើ ប៊ូតុង **កែប្រែប្រតិបត្តិការ** សូមស្វែងរកតាមលេខវិក្កយបត្រ ចុចប៊ូតុង**កែប្រែវិក្កយបត្រ** សូមបំពេញព័ត៌មានឲ្យបានត្រឹមត្រូវ បន្ទាប់មកសូមចុចប៊ូតុង **រក្សាទុក និងបន្ថែមថ្មី**






រូបភាពទី 11 ÷ កែប្រែប្រតិបត្តិការលក់

- ករណីលុបប្រតិបត្តិការលក់ ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ** សូមចុចលើ ប៊ូតុង **លុបប្រតិបត្តិការ** សូមស្វែងរកតាមលេខវិក្កយបត្រ ចុចប៊ូតុង**លុបវិក្កយបត្រ** បន្ទាប់មកសូមបញ្ចូលមូលហេតុ រួចសូមចុចប៊ូតុង **យល់ព្រម**




រូបភាពទី 12 ÷ លុបវិក្កយបត្រលក់

- ករណីមើលព័ត៌មាននៃការកែតម្រូវប្រតិបត្តិការលក់ ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ** សូមចុចលើប៊ូតុង **ពិនិត្យព័ត៌មានលម្អិតនៃការកែតម្រូវ** អាចស្វែងរកតាមលេខវិក្កយបត្រ ឬប្រតិវេទគយ និងលេខសម្គាល់ចុះបញ្ជីពន្ធដារ សូមចុចប៊ូតុង **ស្វែងរក**




រូបភាពទី 13 ៖ មើលព័តិមានការកែតម្រូវប្រតិបត្តិការលក់

➢ **កែតម្រូវចំណាយផ្សេងៗ**

ការកែតម្រូវការចំណាយផ្សេងៗ លោក លោកស្រីអាចបន្ថែមវិក្កយបត្រថ្មីចំពោះការខកខានមិនបានបញ្ចូល អាចកែប្រែព័ត៌មានវិក្កយបត្រដែលខុស ឬអាចលុបវិក្កយបត្រចេញ។

- សូមចុច **ចំណាយផ្សេងៗ**
- ករណីបន្ថែមប្រតិបត្តិការចំណាយផ្សេងៗ ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ**សូមចុចលើ ប៊ូតុង **បន្ថែមប្រតិបត្តិការ** សូមបំពេញព័ត៌មានឲ្យបានត្រឹមត្រូវ បន្ទាប់មកសូមចុចប៊ូតុង **រក្សាទុក និងបន្ថែមថ្មី**






រូបភាពទី 14 ÷ បន្ថែមប្រតិបត្តិការចំណាយផ្សេងៗ

- ករណីកែប្រែប្រតិបត្តិការចំណាយផ្សេងៗ ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ** សូមចុចលើ ប៊ូតុង **កែប្រែប្រតិបត្តិការ** សូមស្វែងរកតាមលេខវិក្កយបត្រ ចុចប៊ូតុង**កែប្រែវិក្កយបត្រ** សូមបំពេញព័ត៌មានឲ្យបានត្រឹមត្រូវ បន្ទាប់មកសូមចុចប៊ូតុង **រក្សាទុក និងបន្ថែមថ្មី**




រូបភាពទី 15 ÷ កែប្រែប្រតិបត្តិការចំណាយផ្សេងៗ

- ករណីលុបប្រតិបត្តិការចំណាយផ្សេងៗ ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ** សូមចុចលើ ប៊ូតុង **លុបប្រតិបត្តិការ** សូមស្វែងរកតាមលេខវិក្កយបត្រ ចុចប៊ូតុង**លុបវិក្កយបត្រ** បន្ទាប់មកសូមបញ្ចូលមូលហេតុ រួចសូមចុចប៊ូតុង **យល់ព្រម**




រូបភាពទី 16 ៖ លុបវិក្កយបត្រចំណាយផ្សេងៗ

- ករណីមើលព័ត៌មាននៃការកែតម្រូវប្រតិបត្តិការចំណាយផ្សេងៗ ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ** សូមចុចលើ ប៊ូតុង **ពិនិត្យព័ត៌មានលម្អិតនៃការកែតម្រូវ** អាចស្វែងរកតាមលេខវិក្កយបត្រ ឬប្រតិវេទគយ និងលេខសម្គាល់ចុះបញ្ជីពន្ធដារ សូមចុចប៊ូតុង **ស្វែងរក**




រូបភាពទី 17 ៖ មើលព័ត៌មានការកែតម្រូវប្រតិបត្តិការចំណាយផ្សេងៗ

### ២.៤.២ បញ្ជីកែតម្រូវពន្ធកាត់ទុក

ការកែតម្រូវពន្ធកាត់ទុក លោក លោកស្រីអាចបន្ថែមវិក្កយបត្រថ្មីចំពោះការខកខានមិនបានបញ្ចូល អាចកែប្រែព័ត៌មានវិក្កយបត្រដែលខុស ឬអាចលុបចោល ពេលដែលប្រកាសពន្ធប្រចាំខែខុស។ សូមលោក លោកស្រីចុចលើម៉ឺនុយ **កែតម្រូវលិខិតប្រកាសពន្ធ** ចុចលើ **បញ្ជីកែតម្រូវពន្ធកាត់ទុក** សូមជ្រើសរើសទីស្នាក់ការ និងកាលបរិច្ឆេទ៖

- ករណីបន្ថែមប្រតិបត្តិការពន្ធកាត់ទុក ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ** សូមចុចលើ ប៊ូតុង**បន្ថែមប្រតិបត្តិការ** សូមបំពេញព័ត៌មានឲ្យបានត្រឹមត្រូវ បន្ទាប់មកសូមចុចប៊ូតុង **រក្សាទុក និងបន្ថែមថ្មី**




រូបភាពទី 18 ៖ បន្ថែមប្រតិបត្តិការពន្ធកាត់ទុក

- ករណីកែប្រែប្រតិបត្តិការពន្ធកាត់ទុក ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ សូម**ចុចលើ ប៊ូតុង **កែប្រែប្រតិបត្តិការ** សូមស្វែងរកតាមលេខវិក្កយបត្រ ចុចប៊ូតុង**កែប្រែវិក្កយបត្រ** សូមបំពេញព័ត៌មានឲ្យបានត្រឹមត្រូវ បន្ទាប់មកសូមចុចប៊ូតុង **រក្សាទុក និងបន្ថែមថ្មី**




រូបភាពទី 19 ÷ កែប្រែប្រតិបត្តិការពន្ធកាត់ទុក

- ករណីលុបប្រតិបត្តិការពន្ធកាត់ទុក ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ សូម**ចុចលើ ប៊ូតុង **លុបប្រតិបត្តិការ** សូមស្វែងរកតាមលេខវិក្កយបត្រ ចុចប៊ូតុង**លុបវិក្កយបត្រ** បន្ទាប់មកសូមបញ្ចូលមូលហេតុ រួចសូមចុចប៊ូតុង **យល់ព្រម**




រូបភាពទី 20 ÷ លុបប្រតិបត្តិការពន្ធកាត់ទុក

- ករណីមើលព័ត៌មាននៃការកែតម្រូវប្រតិបត្តិការពន្ធកាត់ទុក ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ សូម**ចុចលើ ប៊ូតុង **ពិនិត្យព័ត៌មានលម្អិតនៃការកែតម្រូវ** អាចស្វែងរកតាមលេខវិក្កយបត្រ ឬប្រតិវេទគយ និងលេខសម្គាល់ចុះបញ្ជីពន្ធដារ សូមចុចប៊ូតុង **ស្វែងរក**




រូបភាពទី 21 ÷ មើលព័ត៌មានការកែតម្រូវប្រតិបត្តិការពន្ធកាត់ទុក

### ២.៤.៣ បញ្ជីកែតម្រូវពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម

ការកែតម្រូវពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម លោក លោកស្រីអាចបន្ថែមវិក្កយបត្រថ្មីចំពោះការខកខានមិនបានបញ្ចូល អាចកែប្រែព័ត៌មានវិក្កយបត្រដែលខុស ឬអាចលុបចោល ពេលដែលប្រកាសពន្ធប្រចាំខែខុស។ សូមលោក លោកស្រីចុចលើម៉ឺនុយ **កែតម្រូវលិខិតប្រកាសពន្ធ** ចុចលើ **បញ្ជីកែតម្រូវពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម** សូមជ្រើសរើសទីស្នាក់ការ និងកាលបរិច្ឆេទ៖

- ករណីបន្ថែមប្រតិបត្តិការពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ** សូមចុចលើ ប៊ូតុង**បន្ថែមប្រតិបត្តិការ** សូមបំពេញព័ត៌មានឲ្យបានត្រឹមត្រូវ បន្ទាប់មកសូមចុចប៊ូតុង **រក្សាទុក និងបន្ថែមថ្មី**






រូបភាពទី 22 ៖ បន្ថែមប្រតិបត្តិការពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម

- ករណីកែប្រែប្រតិបត្តិការពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ** សូមចុចលើ ប៊ូតុង **កែប្រែប្រតិបត្តិការ** សូមស្វែងរកតាមលេខវិក្កយបត្រ ចុចប៊ូតុង**កែប្រែទិន្នន័យ** សូមបំពេញព័ត៌មានឲ្យបានត្រឹមត្រូវ បន្ទាប់មកសូមចុចប៊ូតុង **រក្សាទុក និងបន្ថែមថ្មី**




រូបភាពទី 23 ៖ កែប្រែប្រតិបត្តិការពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម

- ករណីលុបប្រតិបត្តិការពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ត្រង់ប៊ូតុង**កែតម្រូវប្រតិបត្តិការ** សូមចុចលើ ប៊ូតុង **លុបប្រតិបត្តិការ** សូមស្វែងរកតាមលេខវិក្កយបត្រ ចុចប៊ូតុង**លុបវិក្កយបត្រ** បន្ទាប់មកសូមបញ្ចូលមូលហេតុ រួចសូមចុចប៊ូតុង **យល់ព្រម**



រូបភាពទី 24 ÷ លុបប្រតិបត្តិការពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម

- ករណីមើលព័ត៌មាននៃការកែតម្រូវប្រតិបត្តិការពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ត្រង់ប៊ូតុង **កែតម្រូវប្រតិបត្តិការ** សូមចុចលើ ប៊ូតុង **ពិនិត្យព័ត៌មានលម្អិតនៃការកែតម្រូវ** អាចស្វែងរកតាមលេខវិក្កយបត្រ ឬប្រតិវេទគយ និងលេខសម្គាល់ចុះបញ្ជីពន្ធដារ សូមចុចប៊ូតុង **ស្វែងរក**



រូបភាពទី 25 ÷ មើលព័ត៌មានការកែតម្រូវប្រតិបត្តិការពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម

## ២.៥ ការប្រកាសពន្ធកែតម្រូវប្រចាំខែ

សូមលោក លោកស្រីចុចលើម៉ឺនុយប្រកាសពន្ធកែតម្រូវប្រចាំខែ ចុចលើម៉ឺនុយ**ប្រកាសពន្ធកែតម្រូវប្រចាំខែ** សូមជ្រើសរើសរូបមន្ត និងកាលបរិច្ឆេទ រួចចុចប៊ូតុង**ស្វែងរក** សូមចុចធីកខ្ញុំបានពិនិត្យគ្រប់ចំណុច... សូមចុចប៊ូតុង **រក្សាទុកនិងដាក់ពាក្យស្នើសុំ**




រូបភាពទី 26 ÷ ប្រកាសពន្ធកែតម្រូវប្រចាំខែ

## ២.៦ បញ្ជីប្រកាសពន្ធកែតម្រូវប្រចាំខែ

បន្ទាប់ពីលោក លោកស្រីធ្វើការប្រកាសពន្ធប្រចាំខែរួចហើយ លោក លោកស្រីអាចបោះពុម្ពពាក្យស្នើសុំកែតម្រូវលិខិតប្រកាសពន្ធប្រចាំខែ ឬបោះពុម្ពលិខិតបញ្ជាក់ការបង់ពន្ធ ឬបោះពុម្ពលិខិតអនុញ្ញាតកែតម្រូវ (ករណីអគ្គនាយកដ្ឋានពន្ធដារបានឯកភាព) ឬបោះពុម្ពលិខិតបដិសេធកែតម្រូវ(ករណីអគ្គនាយកដ្ឋានពន្ធដារមិនឯកភាព)

### ២.៦.១ បោះពុម្ពពាក្យស្នើសុំកែតម្រូវ

សូមលោក លោកស្រីចុចលើម៉ឺនុយ**ប្រកាសពន្ធកែតម្រូវប្រចាំខែ** រួចលើម៉ឺនុយ**បញ្ជីប្រកាសពន្ធកែតម្រូវប្រចាំខែ** បន្ទាប់មកសូមចុចលើប៊ូតុង**ស្វែងរក** ត្រង់តារាងជួរឈរ ចុចលើ**បោះពុម្ពពាក្យស្នើសុំកែតម្រូវលិខិតប្រកាសពន្ធប្រចាំខែ** រួចចុចប៊ូតុង**បោះពុម្ព៖**



រូបភាពទី 27 ÷ បោះពុម្ពពាក្យស្នើសុំកែតម្រូវលិខិតប្រកាសពន្ធប្រចាំខែ

### ២.៦.២ បោះពុម្ពលិខិតបញ្ជាក់ការបង់ពន្ធកែតម្រូវ

សូមលោក លោកស្រីចុចលើម៉ឺនុយ**ប្រកាសពន្ធកែតម្រូវប្រចាំខែ** រួចចុចលើម៉ឺនុយ**បញ្ជីប្រកាសពន្ធកែតម្រូវប្រចាំខែ** បន្ទាប់មកសូមចុចលើប៊ូតុង**ស្វែងរក** ត្រង់តារាងជួរឈរ ចុចលើ**បោះពុម្ពលិខិតបញ្ជាក់ការបង់ពន្ធ** រួចចុចប៊ូតុង**បោះពុម្ព**៖




រូបភាពទី 28 ÷បោះពុម្ពលិខិតបញ្ជាក់ការបង់ពន្ធ

### ២.៦.៣ បោះពុម្ពលិខិតអនុញ្ញាតកែតម្រូវ

សូមលោក លោកស្រីចុចលើម៉ឺនុយ**ប្រកាសពន្ធកែតម្រូវប្រចាំខែ** រួចលើម៉ឺនុយ**បញ្ជីប្រកាសពន្ធកែតម្រូវប្រចាំខែ** បន្ទាប់មកសូមចុចលើប៊ូតុង**ស្វែងរក** ត្រង់តារាងជួរឈរ ចុចលើ**បោះពុម្ពលិខិតអនុញ្ញាតកែតម្រូវ** រួចចុចប៊ូតុង**បោះពុម្ព**៖







រូបភាពទី 29 ÷ បោះពុម្ពលិខិតអនុញ្ញាតកែតម្រូវ

### ២.៦.៤ បោះពុម្ពលិខិតបដិសេធកែតម្រូវ

សូមលោក លោកស្រីចុចលើម៉ឺនុយ**ប្រកាសពន្ធកែតម្រូវប្រចាំខែ** រួចចុចលើម៉ឺនុយ**បញ្ជីប្រកាសពន្ធកែតម្រូវប្រចាំខែ** បន្ទាប់មកសូមចុចលើប៊ូតុង**ស្វែងរក** ត្រង់តារាងជួរឈរ ចុចលើ**បោះពុម្ពលិខិតបដិសេធកែតម្រូវ** រួចចុចប៊ូតុង**បោះពុម្ព**៖




រូបភាពទី 30 ៖ បោះពុម្ពលិខិតបដិសេធកែតម្រូវ

# អគ្គនាយកដ្ឋានពន្ធដារ

អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥)
សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ +855 23 886 708 / ទូរសារ៖ +855 23 886 700
សារអេឡិចត្រូនិក៖ gdt@tax.gov.kh / គេហទំព័រ៖ www.tax.gov.kh